**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជារំឭកនៃការស្រង់រូបសំណាកព្រះនាងម៉ារីនៃទន្លេមេគង្គ**
**អរិយក្សត្រថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨**
*យើងមកគោរពព្រះមហាក្សត្រដែលឈ្មោះព្រះយេស៊ូគ្រីស្ត*

អត្ថបទទី១៖ ដន ៧,១៣-១៤
អត្ថបទទី២៖ វវ ១,៥-៨
ដំណឹងល្អ៖ យហ ១៨,៣៣-៣៧

បងប្អូនជាទីស្រឡាញ់!

សូមស្វាគមន៍បងប្អូនទាំងអស់ ដែលបានចូលរួមពិធីបុណ្យយ៉ាងឱឡារិក គឺរំលឹកខួបនៃការស្រង់រូបសំណាកព្រះនាងម៉ារីណីទន្លេមេគង្គ និងគោរពព្រះយេស៊ូដែលជាព្រះមហាក្សត្រនៃពិភពលោក។ ថ្ងៃនេះជាឱកាសមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់ ជាពិសេសដើម្បីស្តាប់សំណួរដែលលោកភីឡាត់បានសួរដល់ព្រះយេស៊ូថា "**តើអ្នកជាស្តេចរបស់ជនជាតិយូដាមែនឬ?**" ព្រះយេស៊ូបានឆ្លើយថា "**រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ**"។ ថ្ងៃនេះឲ្យយើងរិះគិត តើព្រះយេស៊ូជាព្រះមហាក្សត្ររបស់យើងទាំងអស់គ្នារបៀបណា? ថ្ងៃនេះបងប្អូនមកយ៉ាងច្រើនប្រហែលជាង៣០០០នាក់ ណែនាំឲ្យយើងដឹងថាពិតមែនយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ពិតមែនយើងជាព្រះរាជ្យរបស់ព្រះជាម្ចាស់។ ពេលប្រជាជនគេឃើញបងប្អូនមកចូលរួមយ៉ាងច្រើនក្នុងពិធីបុណ្យនេះ ខ្ញុំជឿថាគេឆ្ងល់តើគ្រីស្តបរិស័ទទាំងនេះគេមកធ្វើអ្វីនៅទីនេះ? យើងមកគោរពព្រះជាម្ចាស់ យើងមកគោរពព្រះនាងម៉ារី ជាពិសេសយើងមកគោរពព្រះយេស៊ូដែលជាព្រះមហាក្សត្រ។ ប៉ុន្តែ បើយើងឆ្លើយដូចនេះណែនាំឲ្យប្រជាជនដែលមិនមែនជាគ្រីស្តបរិស័ទ សួរខ្លួនឯងថា តើធ្វើដូចម្តេចដើម្បីគោរពព្រះយេស៊ូជាព្រះមហាក្សត្រ ព្រោះនៅកម្ពុជាយើងមានព្រះមហាក្សត្រហើយ? ប៉ុន្តែថ្ងៃនេះយើងមកគោរពព្រះមហាក្សត្រតាមជំនឿ យើងមិនមកគោរពព្រះមហាក្សត្រតាមសង្គម គឺយើងមកគោរពព្រះមហាក្សត្រដែលឈ្មោះព្រះយេស៊ូគ្រីស្ត។

**ចំណុចទីមួយ** ព្រះយេស៊ូមានព្រះហឫទ័យស្រឡាញ់យើង ជាមូលហេតុយើងមកថ្ងៃនេះដោយសារយើងដឹងថាព្រះយេស៊ូស្រឡាញ់យើង។ ជីវិតរបស់ព្រះយេស៊ូ គឺពោរពេញដោយសេចក្តីស្រឡាញ់សម្រាប់មនុស្សទាំងអស់។ សេចក្តីស្រឡាញ់ដែលព្រះយេស៊ូមានចំពោះយើង មិនមែនជាសេចក្តីស្រឡាញ់ល្មមៗទេ គឺជាសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ ដោយសុខចិត្តបូជាជីវិតលើឈើឆ្កាង។ ដូច្នេះពេលព្រះយេស៊ូបានសោយទិវង្គត យើងឃើញជាក់ស្តែងព្រះយេស៊ូស្រឡាញ់ខ្លាំងណាស់។

**ចំណុចទីពីរ** ព្រះមហាក្សត្រយើងបានរំដោះយើងឲ្យរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអម្ចាស់ផ្ទាល់។ សប្តាហ៍ក្រោយយើងចូលនៅក្នុងរដូវរង់ចាំ ដើម្បីត្រៀមខ្លួនទទួលព្រះ

យេស៊ូដែលចាប់កំណើតជាមនុស្ស ដើម្បីណែនាំឲ្យមនុស្សលោកទទួលជីវិតអស់កល្បជានិច្ច។ នៅថ្ងៃដែលព្រះយេស៊ូប្រសូតនៅក្នុងភូមិបេថ្លេហិម ដែលមានគ្រូគង្វាលផង ដែលមានហោរាចារ្យផង ដែលមានប្រជាជនធម្មតាផង ដែលមានទេវទូតផង ដើម្បីកោតសរសើរព្រះយេស៊ូដែលចាប់ផ្ដើមចូលនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោក ដើម្បីរំដោះយើងពីបាប។ នៅពេលព្រះយេស៊ូនៅលើឈើឆ្កាង មានឈាមដែលចេញពីព្រះអង្គ មានទឹកដែលចេញពីឆ្អឹងជំនីរបស់ព្រះអង្គ ដើម្បីណែនាំឲ្យយើងទទួលព្រះពរ និងណែនឲ្យយើងទទួលជីវិតថ្មី។ ចាប់ពីពេលនេះតទៅ ជីវិតរបស់យើងមិនមែនដូចគ្នាទេ ដោយសារព្រះយេស៊ូណែនាំឲ្យសេចក្ដីស្លាប់ឈ្នះ ណែនាំឲ្យភាពងងឹតទៅជាពន្លឺ សេចក្ដីស្លាប់ទៅជាជីវិតអស់កល្បជានិច្ច។ លែងមានអំពើឃោឃៅ លែងមានសេចក្ដីស្លាប់ដែលឈ្នះលើយើង យើងដឹងថាអ្វីៗទាំងអស់ដែលព្រះយេស៊ូប្រទានឲ្យឈ្នះលើអ្វីៗទាំងអស់ មានន័យថាព្រះយេស៊ូបានណែនាំឲ្យយើងទទួលជីវិតដ៏បរិបូរណ៍។

**ចំណុចទីបី** ព្រះអង្គបានធ្វើឲ្យយើងទៅជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹកយើងទៅជាបុត្រធីតារបស់ព្រះអង្គ។ យើងចូលនៅក្នុងមហាគ្រួសាររបស់ព្រះអង្គ និងណែនាំឲ្យយើងទៅជាព្រះរាជ្យរបស់ប្រជាជនព្រះអង្គយ៉ាងពិតប្រាកដមែន នៅក្នុងព្រះរាជ្យរបស់ព្រះអង្គដែលចាប់ផ្ដើមពីពេលនេះតទៅ។

**ចំណុចទីបួន** ព្រះជាម្ចាស់បានណែនាំឲ្យយើងធ្វើជាក្រុមបូជាចារ្យបម្រើព្រះជាម្ចាស់ មិនមែនតែលោកបូជាចារ្យ លោកអភិបាល តែយើងទាំងអស់យើងជាក្រុមបូជាចារ្យបម្រើព្រះជាម្ចាស់ មានន័យថាយើងជាអ្នកដែលអធិដ្ឋាន ថ្វាយបង្គំ ទូលអង្វរព្រះអង្គ ដើម្បីទទួលជីវិត និងយើងជាអ្នកបម្រើព្រះជាម្ចាស់អស់ពីដួងចិត្ត។

ទាំងបួនចំណុចខាងលើ ជាសិទ្ធិរបស់យើងមានន័យថា ព្រះជាម្ចាស់ស្រឡាញ់យើង ព្រះជាម្ចាស់រំដោះយើង ព្រះជាម្ចាស់ណែនាំឲ្យយើងចូលនៅក្នុងព្រះរាជ្យរបស់ព្រះអង្គ ព្រះជាម្ចាស់តែងតាំងយើងជាបូជាចារ្យដើម្បីបម្រើព្រះរាជ្យព្រះអង្គ។ មានន័យថា យើងមានតួនាទីដែរ មិនមែនតែសិទ្ធិទទួលតែយើងមានតួនាទីដើម្បីគោរពសិទ្ធិរបស់យើង។ ខ្ញុំចង់ឲ្យយើងគិតរួមជាមួយព្រះនាងម៉ារី តើយើងធ្វើយ៉ាងដូចម្ដេច ដើម្បីគោរពតួនាទីរបស់យើងជាគ្រីស្តបរិស័ទដ៏ពិតប្រាកដ? សិទ្ធិរបស់យើងព្រះជាម្ចាស់ ព្រះយេស៊ូស្រឡាញ់យើង តើយើងធ្វើដូចម្ដេចដើម្បីឲ្យព្រះជាម្ចាស់ស្រឡាញ់យើង? តើយើងធ្វើដូចម្ដេចដើម្បីទទួលស្វាគមន៍សេចក្ដីស្រឡាញ់របស់ព្រះអង្គនៅក្នុងជីវិតរបស់យើង? រូបព្រះនាងម៉ារី គេបានរកឃើញនៅថ្ងៃដែលឪពុកម្ដាយព្រះនាងម៉ារីថ្វាយព្រះនាងម៉ារីទៅព្រះជាម្ចាស់ ពីពេលនោះព្រះនាងម៉ារីបានចូលជាមួយព្រះជាម្ចាស់ ទុកឲ្យព្រះជាម្ចាស់ស្រឡាញ់ព្រះនាងអស់ពីសមត្ថភាព។ ណែនាំឲ្យព្រះនាងម៉ារី អាចឆ្លើយតបថា "**នាងខ្ញុំជាអ្នកបម្រើព្រះជាម្ចាស់ សូមឲ្យបានសម្រេចតាមព្រះហឫទ័យព្រះជាម្ចាស់**" ប្រសិនបើព្រះ

នាងម៉ារីមិនបើកចិត្តគំនិតដើម្បីអធិដ្ឋាន ព្រមទទួលសេចក្តីស្រឡាញ់ពីព្រហាជាម្ចាស់ គាត់ធ្វើដូចម្តេចដើម្បីទទួលដំណឹងល្អធ្វើជាមាតារបស់ព្រះយេស៊ូបាន។ យើងត្រូវការគិត ខ្ញុំជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ខ្ញុំធ្វើយ៉ាងណា ដើម្បីទទួលស្វាគមន៍សេចក្តីស្រឡាញ់របស់ព្រះអង្គដូចព្រះនាងម៉ារី?

យើងមានសិទ្ធិទទួលការរំដោះបាប ប៉ុន្តែយើងធ្វើដូចម្តេចដើម្បីឲ្យព្រះជាម្ចាស់រំដោះបាបយើង? តើយើងយកចិត្តទុកដាក់កែប្រែចិត្តគំនិត យកចិត្តទុកដាក់ទទួលជីវិតថ្មីអ្វីខ្លះពីមួយថ្ងៃទៅមួយថ្ងៃ? ពេលយើងចូលនៅក្នុងរដូវរង់ចាំ ជាឱកាសមួយដើម្បីឲ្យយើងកែប្រែចិត្តកំនិតរបស់យើងបន្តិចម្តងៗ ដើម្បីទទួលជីវិតថ្មី ដើម្បីឲ្យព្រះអង្គរំដោះយើងពីបាបយ៉ាងពិតប្រាកដមែន។ ឲ្យយើងមើលជីវិតរបស់ព្រះនាងម៉ារី យើងអធិដ្ឋានរាល់ពេលយើងសូត្រផ្គាំ ពីថ្ងៃដែលព្រះនាងម៉ារីបានទទួលដំណឹងល្អពីទេវទូតកាព្រីអែល ព្រះនាងម៉ារីបានប្រសូតព្រះយេស៊ូនៅភូមិបេថ្លេហឹម ពីថ្ងៃដែលព្រះនាងម៉ារីនៅក្បែរឈើឆ្កាង ពីថ្ងៃដែលព្រះនាងម៉ារីទៅសួននៃជីវិតរស់ឡើងវិញរបស់ព្រះយេស៊ូ រហូតដល់ព្រះនាងម៉ារីគង់នៅនៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក និងព្រះនាងម៉ារីបានឡើងស្ថានបរមសុខ នេះជាជីវិតរបស់ព្រះនាងម៉ារីដើម្បីទទួលជីវិតថ្មី។ ព្រះនាងម៉ារីគ្មានជំពាក់បាប ដូច្នេះព្រះនាងម៉ារីជាប់ជាមួយព្រះជាម្ចាស់តែម្តង។ ប៉ុន្តែសម្រាប់យើងដែលជំពាក់បាប តើយើងធ្វើដូចម្តេចដើម្បីកែប្រែចិត្តគំនិត ទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូដូចព្រះនាងម៉ារីពីដើម?

យើងមានសិទ្ធិធ្វើជាប្រជាជននៅក្នុងព្រះរាជ្យរបស់ព្រះអង្គ ប៉ុន្តែយើងធ្វើដូចម្តេចដើម្បីប្រកាសព្រះរាជ្យរបស់ព្រះអង្គដោយសេចក្តីពិត ដោយសកម្មភាពជាក់ស្តែង ដូចព្រះនាងម៉ារីនៅពេលព្រះនាងបានទៅភូមិហ្កាណា ព្រះនាងម៉ារីបាននិយាយថា "**សូមធ្វើតាមព្រះបន្ទូលព្រះជាម្ចាស់ជានិច្ច**" តើយើងធ្វើយ៉ាងដូចម្តេច ដើម្បីធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតយើង? ជាពិសេសនៅថ្ងៃនេះ ដែលយើងគោរពព្រះយេស៊ូជាព្រះមហាក្សត្រ ជាអ្នបម្រើ តើយើងធ្វើដូចម្តេចដើម្បីបម្រើបងប្អូនឯទៀតៗ? តើយើងធ្វើដូចម្តេចដើម្បីស្រឡាញ់? តើយើងធ្វើដូចម្តេចដើម្បីយកចិត្តទុកដាក់ជាមួយមនុស្សតូចតាច? តើយើងធ្វើដូចម្តេចដើម្បីមើលឃើញអយុត្តិធម៌នៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ? តើយើងធ្វើដូចម្តេចដើម្បីលើកទឹកចិត្តដល់មនុស្សដែលគ្មានផ្លូវនៅក្នុងជីវិត?

អ្វីៗទាំងអស់ខាងលើរកឃើញចម្លើយដល់កំពូល គឺព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យទៅជាក្រុមបូជាចារ្យដែលបម្រើព្រះជាម្ចាស់ យើងជាអ្នកបម្រើ។ ព្រះមហាក្សត្ររបស់យើង បានលាងជើងដល់ក្រុមសាវ័ក ព្រះមហាក្សត្ររបស់យើងគឺព្រះយេស៊ូបម្រើយើងជានិច្ច។ ដូច្នេះយើងធ្វើដូចម្តេចដើម្បីបម្រើទាំងព្រះជាម្ចាស់ ទាំងបងប្អូនឯទៀតៗ។ ខ្ញុំសង្ឃឹមពេលយើងទៅផ្ទះវិញយើងធ្វើដូចម្តេចដើម្បីបើកភ្នែកមើលសង្គមយើង មើលបងប្អូនឯទៀតៗ ដើម្បីគិតថាខ្ញុំជាគ្រីស្ត

បរិស័ទ ខ្ញុំមានឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ ខ្ញុំមានឋានៈជាបូជាចារ្យរបស់ព្រះអង្គ ខ្ញុំមានឋានៈជាព្រះមហាក្សត្ររបស់ព្រះអង្គ តើខ្ញុំធ្វើដូចម្តេចដើម្បីបម្រើបងប្អូនឯទៀតៗអស់ពីដួងចិត្ត? យើងបានយកចិត្តទុកដាក់ធ្វើដំណើរមកទីនេះ ដើម្បីគោរពព្រះនាងម៉ារី យើងយកចិត្តទុកដាក់ធ្វើដំណើរទៅផ្ទះរបស់យើងដើម្បីគោរពបងប្អូនឯទៀតៗ ដើម្បីធ្វើជាសាក្សីនៃសេចក្តីពិតដូចព្រះយេស៊ូបានជួបជាមួយលោកប៉ុលពីឡាត់។ សេចក្តីពិតដែលណែនាំឲ្យមនុស្សតូចតាចឈរឡើង ណែនាំឲ្យមនុស្សដែលគ្មានសេចក្តីសង្ឃឹមបានពោរពេញដោយជីវិត ណែនាំឲ្យមនុស្សខ្វាក់មើលឃើញ ណែនាំឲ្យយើងអាចប្រកាសព្រះវាជ្យរបស់ព្រះជាម្ចាស់ពិតមែន។

ម្សិលមិញយើងបានគោរពមរណសាក្សីនៅប្រទេសវៀតណាម សន្តអន់ជ្រេនិងសហការីមរណសាក្សីជាគំរូ ដែលបានលះបង់ចោលអ្វីៗទាំងអស់។ ដូច្នេះសព្វថ្ងៃ យើងត្រូវការលះបង់ចោលខ្លះដែរ ដើម្បីទៅជាសាក្សីនៃជីវិតដូចមរណៈសាក្សីពីដើម។ ម្សិលមិញលោកអភិបាលនៅប្រទេសវៀតណាម បានទេសនាអំពីព្រះសហគមន៍នៅប្រទេសកម្ពុជា ព្រះសហគមន៍នៅប្រទេសកម្ពុជាជាព្រះសហគមន៍តូច ប៉ុន្តែអ្វីដែលជាសំខាន់ យើងធ្វើដូចម្តេចដើម្បីទៅជាក្រុមគ្រួសារតែមួយ ដែលចេះស្រឡាញ់ ដែលចេះអធិដ្ឋាន ដែលចេះគោរពគ្នាទៅវិញទៅមក និងដែលចេះបម្រើជានិច្ច។ ពេលយើងធ្វើដំណើរទៅវិញ ឲ្យយើងគិតពិចារណាថ្ងៃណោះយើងបានជួបជាមួយព្រះនាងម៉ារី ថ្ងៃនេះយើងបានជួបជាមួយព្រះយេស៊ូ ពេលចូលនៅក្នុងរដូវរង់ចាំ ខ្ញុំធ្វើដូចម្តេចដើម្បីរៀបចំចិត្តគំនិត? ខ្ញុំធ្វើដូចម្តេចដើម្បីផ្តល់សក្ខីភាពជាក់ស្តែង ខ្ញុំជាបុត្រធីតារបស់ព្រះជាម្ចាស់ ខ្ញុំចង់ឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គទៅគ្រប់ទីកន្លែង និងក្នុងជីវិតរបស់ខ្ញុំ។

សូមព្រះជាម្ចាស់ប្រទានពរដល់យើងទាំងអស់គ្នា ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន៕